**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កងរាជអាវុធហត្ថរាជធានីភ្នំពេញ**
**មណ្ឌលបញ្ជាប្រតិបត្តិការ**
**លេខ ១៣៥/២០២០ របក**

ថ្ងៃសុក្រ ៨កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០

# របាយការណ៍ប្រចាំថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០

( ចាប់ពីម៉ោង 16:00 ថ្ងៃទី 28 ដល់ម៉ោង 16:00 ថ្ងៃទី 29 ខែឧសភា ឆ្នាំ2020 )

## II-**លទ្ធផលអនុវត្តតួនាទីភារកិច្ចកងរាជអាវុធហត្ថ** :

### 1-**លទ្ធផលការងារការពារសន្តិសុខ និង រក្សាសណ្តាប់ធ្នាប់** :

-ប្រើប្រាស់កម្លាំងសរុប 1.005 នាក់ រថយន្ត 15 គ្រឿង ម៉ូតូ 405 គ្រឿង ធ្វើសកម្មភាព 09 លើក ក្នុងនោះ ៖

-ការពារថ្នាក់ដឹកនាំជាន់ខ្ពស់ 05 លើក ប្រើប្រាស់កម្លាំង 200 នាក់ ម៉ូតូ 100 គ្រឿង ។





-សហការការពារគោលដៅ ទីតាំងត្រួតពិនិត្យធ្វើចត្តាឡីស័ក ខណ្ឌពោធិសែនជ័យប្រើប្រាស់កម្លាំង 10 នាក់ ម៉ូតូ 05 គ្រឿង ។





-សហការចុះត្រួតពិនិត្យអាវុធជាតិផ្ទុះ ប្រើប្រាស់កម្លាំង 130 នាក់ ម៉ូតូ 65 គ្រឿង ។





-ការពារគោលដៅល្បាតពួនស្ទាក់ និង សម្រួលសណ្តាប់ធ្នាប់ចរាចរណ៍ប្រើប្រាស់កម្លាំង 445 នាក់ រថយន្ត 05 គ្រឿង ម៉ូតូ 175 គ្រឿង ។





-កម្លាំងត្រៀមអន្តរាគមន៍រហ័ស 220 នាក់ រថយន្ត 10 ម៉ូតូ 60 គ្រឿង ។




2-**លទ្ធផលការងារហ្វឹកហ្វឺន និង កីឡា ៖**

-**លទ្ធផលការងារកីឡា** :

-គ្រប់បណ្តាកងឯកភាពចំណុះកងរាជអាវុធហត្ថរាជធានីភ្នំពេញឆ្លៀតឱកាសពេលទំនេរ ក្រៅការងារតែងតែយកចិត្តទុកដាក់អនាម័យ និង ហាត់ប្រាណ លេងកីឡា ដើម្បីសុខភាពផ្ទាល់ខ្លួន ។





III-**សកម្មភាព-លទ្ធផលការងារកងរាជអាវុធហត្ថធ្វើបាន** :

1-**លទ្ធផលការងារអនាម័យអង្គភាព និង សុខភាពកងទ័ព** :

-ជារៀងរាល់ថ្ងៃ គ្រប់បណ្តាកងឯកភាពចំណុះ បានយកចិត្តទុកដាក់សំអាតអនាម័យជាប្រចាំក្នុងអង្គភាព តាមកន្លែងការិយាល័យធ្វើការ និង ទីធ្លាសាធារណ: ចំពោះបញ្ហាសុខភាពបានផ្សព្វផ្សាយជាប្រចាំក្នុងនោះការិយាល័យសុខាភិបាលបានពិនិត្យព្យាបាលជូនបងប្អូនបាន 13 នាក់ ។





2-**លទ្ធផលការពារសន្តិសុខ និង រក្សាសណ្តាប់ធ្នាប់អង្គភាព** :

-គ្រប់បណ្តាកងឯកភាពចំណុះបញ្ជាការដ្ឋាន រាល់ការងារការពារសន្តិសុខ-រក្សាសណ្តាប់ធ្នាប់អង្គភាព បានយកចិត្តទុកដាក់ជាប្រចាំ ការយាមកាម ប្រចាំបញ្ជាប្រចាំការ ប្រតិបត្តិការ ត្រូវបានពង្រឹង អនុវត្តតាមបទបញ្ជា ( វិន័យ ឋានានុក្រមរបៀបរបបធ្វើការងារ អនុវត្តយ៉ាងម៉ឺងម៉ាត់ ) ។





3-**លទ្ធផលការថែទាំមធ្យោបាយ យោធបរិក្ខារគ្រឿងបំពាក់** :

-គ្រប់បណ្តាកងឯកភាពចំណុះកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានយកចិត្តទុកដាក់ មានកម្មវិធីច្បាស់លាស់លើការងារជួសជុល ជូតលាងនូវ មធ្យោបាយតូចធំបរិក្ខារគ្រឿងបំពាក់ អនាម័យជាប់ជានិច្ច ។






4-**លទ្ធផលការងារជួយប្រជាពលរដ្ឋនិងកិច្ចការសង្គម** :

-ក្រុមការងារគ្រូពេទ្យកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានយករថយន្តសង្គ្រោះទៅដល់ផ្ទះអ្នកជំងឺម្នាក់ឈ្មោះ តាំង មករា នៅសង្កាត់ព្រៃកំពឹស ដែលខ្វះខាតជីវភាព ដើម្បីមកទទួលការពិនិត្យ និង សម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដោយយើងធានារ៉ាប់រងលើថ្លៃសេវាជំនួសគាត់ ។





## ព័ត៌មាន-ជាតិ

### ១.ករណីទាមទារដីទំនាស់នៅតំបន់អតីតខ្មែរក្រហមឃុំទួលពង្រស្រុកម៉ាឡៃ ៖ មន្ត្រីនឹងធ្វើអត្តសញ្ញាណកម្មមនុស្សនិងចុះវាស់វែង ធ្វើអត្តសញ្ញាណកម្មដី ដកស្រង់ពី(វស្មីកម្ពុជា) 29.05.2020



ករណីទាមទារដីទំនាស់ដែលសេចក្តីជូនដំណឹង(សជណ)របស់ទីស្តីការគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលបានធ្វើនិរាករណ៍ទៅហើយ១កន្លែងទៀតនៅតំបន់អតីតខ្មែរក្រហមឃុំទួលពង្រស្រុកម៉ាឡៃ ភាគីដើមបណ្តឹងអះអាងថាយល់ព្រមអោយមន្ត្រីអាជ្ញាធរដែនដីធ្វើអត្តសញ្ញាណកម្មមនុស្សដែលថាជាយោធិននិងគ្រួសារអតីតខ្មែរក្រហមដែលមិនទាន់បានគោលរបបដី និងក៏អោយមន្ត្រីសុរិយោដីចុះវាស់វែង ធ្វើអត្តសញ្ញាណកម្មដីផងដែរ ។ (អានបន្ត)

### ២.សមត្ថកិច្ចឃាត់ខ្លួនជនសង្ស័យប្តីប្រពន្ធពីរនាក់ពាក់ពន្ធនឹងគ្រឿងញៀន ដកស្រង់ពី(វស្មីកម្ពុជា) 29.05.2020



ថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ២០២០កម្លាំងប្រឆាំងគ្រឿង ញៀននៃស្នងការខេត្តឧត្តរមានជ័យ ឃាត់ខ្លួនជនសង្ស័យប្តីប្រពន្ធពីរនាក់ក្នុងករណី ចែកចាយនិងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ស្ថិតនៅ ភូមិគោកឈូក សង្កាត់កូនក្រៀលក្រុងសំរោង។(អានបន្ត)

### ៣.អ្នកគ្រប់គ្រងភ្ញៀវបន្តអំពាវនាវដល់ទេសចរជិតឆ្ងាយឱ្យបង្កើនការប្រុងប្រយ័ត្នចំពោះជំងឺកូវីដ១៩

ដកស្រង់ពី(វស្មីកម្ពុជា) 29.05.2020



មួយរយៈចុងក្រោយនេះ បរិមាណភ្ញៀវសម្រុកមកទស្សនាកម្សាន្តក្នុងខេត្តកំពត ហាក់ឡើងខ្ពស់រហូតធ្វើឱ្យប្រតិបត្តិករទេសចរណ៍ ចាប់ផ្តើមបើកសេវាកម្មរបស់ខ្លួនឡើងវិញយ៉ាងផុលផុស។ ជំនួសឱ្យក្តីបារម្ភចំពោះស្ថានភាពបែបនោះ មន្ត្រីជំនាញបានបន្តណែនាំ និងអំពាវនាវដល់ភ្ញៀវទាំងអស់ត្រូវបង្កើនការប្រុងប្រយ័ត្នអំពីជំងឺកូវីដ១៩ស្របតាមការណែនាំរបស់ក្រសួងសុខាភិបាល។(អានបន្ត)

### ៤.ប្រជាពលរដ្ឋឲ្យកូនស្វាពីរក្បាលទៅមន្ទីរបរិស្ថានខេត្ត ដើម្បីលែងវាចូលទៅក្នុងព្រៃវិញ

ដកស្រង់ពី(វស្មីកម្ពុជា) 29.05.2020



នៅរសៀលថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០នេះ ក្រុមការងារអភិរក្សសត្វព្រៃចល័តរបស់មន្ទីរបរិស្ថានខេត្តមណ្ឌលគិរី សហការជាមួយអង្គការ WWF បានប្រគល់កូនសត្វស្វាចំនួន២ក្បាល ទៅឲ្យមន្ត្រីជំនាញអភិរក្សសត្វព្រៃនៃអង្គការសម្ព័ន្ធមិត្តសត្វព្រៃ ដើម្បីបន្តការថែទាំ ការពារ និងអភិរក្ស ខណៈសត្វស្វាទាំង២ក្បាលនេះត្រូវបានប្រជាពលរដ្ឋរស់នៅក្នុងខេត្តមណ្ឌលគិរី ប្រគល់មកឲ្យមន្ទីរបរិស្ថានខេត្តមណ្ឌលគិរី។(អានបន្ត)

## ៥.ក្រសួងសុខាភិបាល ប្រកាសជូនដំណឹង ពីវិធានការការពារ និងទប់ស្កាត់ជំងឺគ្រុនឈាម ក្នុងរដូវវស្សា ឆ្នាំ២០២០

ដកស្រង់ពី(រស្មីកម្ពុជា) 29.05.2020



យោងតាមសេចក្តីជូនដំណឹង ស្តីពីវិធានការការពារ និងទប់ស្កាត់ ជំងឺគ្រុនឈាម ក្នុងរដូវវស្សា ឆ្នាំ២០២០ ក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជន និងអាជ្ញាធរ គ្រប់លំដាប់ថ្នាក់ទាំងអស់ មេត្តាជ្រាបថា ជំងឺគ្រុនឈាម ក្នុងអំឡុង ១៩ សប្តាហ៍ ដើមឆ្នាំ២០២០ មានចំនួន ២.១៧២ ករណី ដែលចំនួនករណីឈឺ នឹងអាចបន្តកើនឡើង នៅតាមភូមិ ឃុំ និងទីប្រជុំជន នៃបណ្តាខេត្ត នាពេលខាងមុខនេះ។(អានបន្ត)

## ៦.បែងចែកតំបន់គ្រប់គ្រងបោះបង្គោលព្រំប្រទល់និងចុះបញ្ជីដីរដ្ឋនៅដែនជម្រកសត្វព្រៃ

ដកស្រង់ពី(រស្មីកម្ពុជា) 29.05.2020



ព្រះវិហារ:កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០លោកស៊ូ សិរី អភិបាលខេត្តស្តីទី និងក្រុមការងារថ្នាក់ខេត្តអញ្ជើញក្នុងកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីរៀបចំកំណត់បែងចែកតំបន់គ្រប់គ្រងបោះបង្គោលព្រំប្រទល់និងចុះបញ្ជីដីរដ្ឋនៅដែនជម្រកសត្វព្រៃ"ព្រៃឡង់"និងតាមបណ្តាតំបន់ការពារធម្មជាតិភូមិសាស្ត្រខេត្តព្រះវិហារ។

(អានបន្ត)

## ៧. ២៨ថ្ងៃ: ផាកពិន័យយានយន្តជាង៤ម៉ឺនគ្រឿង , ១០៣នាក់ស្លាប់គ្រោះថ្នាក់ចរាចរណ៍

ដកស្រង់ពី(រស្មីកម្ពុជា) 29.05.2020



យានយន្តប្រមាណជាងបួនម៉ឺនគ្រឿង ត្រូវបានផាកពិន័យ នៅក្នុងការអនុវត្តការរឹតបន្តឹងការច្បាប់ចរាចរណ៍ផ្លូវគោក រយ:ពេល ២៨ថ្ងៃ គឺគិតចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី២៨ ខែឧសភា និងគ្រោះថ្នាក់ចរាចរណ៍រយ:ពេល ២៨ថ្ងៃ (១-២៨ ឧសភា) បានបណ្តាលឲ្យមនុស្សស្លាប់ ១០៣នាក់ និងរបួសចំនួន២៨៥នាក់។(អានបន្ត)

## ៨. ប្រមុខការពារជាតិ: សិក្ខាកាមយោធាកម្ពុជាបីនាក់នៅរុស្ស៊ីបានជាសះស្បើយពីជំងឺកូវីដ១៩

ដកស្រង់ពី(រស្មីកម្ពុជា) 29.05.2020



សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ បានមានប្រសាសន៍ប្រាប់រស្មីកម្ពុជានៅថ្ងៃទី២៩ខែឧសភានេះថា សិក្ខាកាមយោធាកម្ពុជាដែលកំពុងសិក្សានៅសហព័ន្ធរុស្ស៊ីចំនួនបីនាក់ ដែលបានឆ្លងជំងឺកូវីដ ១៩ បានជាសះស្បើយអស់ហើយ។ (អានបន្ត)

## ៩.សហព័ន្ធកីឡាសូហ្វតិន្ទីសកម្ពុជា ការបាញ់ថ្នាំសម្លាប់មេរោគ ក្នុងបរិវេណហ្វឹកហាត់ដកស្រង់ពី(រស្មីកម្ពុជា) 29.05.2020




កាលពីរសៀល ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ លោកឧត្តមសេនីយ៍ឯក ជា ប៊ុនហេង ប្រធានអង្គភាពកីឡា នគរបាលជាតិកម្ពុជា និងជាអនុប្រធានទី១ សហព័ន្ធកីឡាសូហ្វតិន្ទីស បានចុះដឹកនាំមន្ត្រីធ្វើការបាញ់ថ្នាំសម្លាប់មេរោគ នៅក្នុងបរិវេណទីលាន សហព័ន្ធកីឡាសូហ្វតិន្ទីសកម្ពុជា នៃពហុកីឡដ្ឋាន ជាតិអូឡាំពិក។(អានបន្ត)

## ១០. រដ្ឋមន្ត្រីក្រសួងសុខាភិបាល ទទួលថវិកាឧបត្ថម្ភជាង១៥ម៉ឺនដុល្លារ ពីក្រសួងការបរទេសសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ១៩ដកស្រង់ពី(Fresh News) 29,05.2020



រដ្ឋមន្ត្រីក្រសួងសុខាភិបាល លោកសាស្ត្រាចារ្យ ម៉ម ប៊ុនហេង បានទទួលថវិកាឧបត្ថម្ភចំនួន ១៥៥,០០០ដុល្លារ ពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីប្រើប្រាស់សម្រាប់ទប់ស្កាត់ និងប្រយុទ្ធនឹងជំងឺកូវីដ១៩។(អានបន្ត)

## ១១.ស្ថានទូតនៃសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា ប្រគល់ថវិកា ២០ម៉ឺនដុល្លារ និងសម្ភារ សម្រាប់ប្រើប្រាស់ប្រយុទ្ធនឹងជំងឺកូវីដ១៩ ជូនដល់ក្រសួងសុខាភិបាលដកស្រង់ពី(Fresh News) 29,05.2020



ស្ថានទូតនៃសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០នេះ បានប្រគល់ថវិកាចំនួន២០ម៉ឺនដុល្លារ និងសម្ភារ សម្រាប់ប្រើប្រាស់ ក្នុងការទប់ស្កាត់ និងប្រយុទ្ធនឹងជំងឺកូវីដ១៩ ជូនដល់ក្រសួងសុខាភិបាល។(អានបន្ត)

## ១២.អាជ្ញាធរក្រុងសិរីសោភ័ណ ណែនាំដល់អាជ្ញាធរនៅមូលដ្ឋាន ត្រូវត្រៀមជាបណ្តើរៗ នូវសម្ភារសង្គ្រោះបន្ទាន់ ទប់ស្កាត់គ្រោះទឹកជំនន់ ដែលនឹងអាចកើតមានឡើង នៅរដូវវស្សាដកស្រង់ពី(Fresh News) 29,05.2020



អាជ្ញាធរក្រុងសិរីសោភ័ណ បានណែនាំដល់អាជ្ញាធរនៅមូលដ្ឋានត្រៀមបង្ការ ទប់ស្កាត់គ្រោះទឹកជំនន់ ខណៈរដូវវស្សាបានចូលមកដល់ ដូច្នេះសូមអាជ្ញាធរមូលដ្ឋាន អ្នកពាក់ព័ន្ធត្រូវត្រៀមឲ្យបានរួចជាស្រេច ក្នុងករណីចាំណាមួយ ក្នុងការជួយសង្គ្រោះបានទាន់ពេលវេលា។ (អានបន្ត)

## ១៣.គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ចុះបង្ក្រាបទីតាំងផលិតផលក្លែងក្លាយមួយកន្លែង នៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដកស្រង់ពី(Fresh News) 29,05.2020



គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ នៃក្រសួងមហាផ្ទៃ បានចុះបង្ក្រាបទីតាំងផលិតផលក្លែងក្លាយមួយកន្លែង នៅចំណុចភ្នំក្រោល ភូមិស្បា ឃុំយាអង្គ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។(អានបន្ត)

## ១៤.ប្រកាសផ្ទេរភារកិច្ច តែងតាំងមុខតំណែង និងបំពាក់ឋានន្តរស័ក្តិ ជូនមន្ត្រីនគរបាលជាតិ ចំណុះគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ និងមន្ទីរពិសោធន៍ផលិតផលក្លែងក្លាយដកស្រង់ពី(Fresh News) 29,05.2020



ក្រសួងមហាផ្ទៃ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០នេះ បានធ្វើពិធីប្រកាសសម្រួលភារកិច្ច ផ្ទេរភារកិច្ច តែងតាំងមុខតំណែង និងបំពាក់ឋានន្តរស័ក្តិជូនមន្ត្រីនគរបាលជាតិ ចំណុះគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ និងមន្ទីរពិសោធន៍ផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់ មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាព។(អានបន្ត)

## ១៥.រដ្ឋបាលរាជធានីភ្នំពេញ នឹងបញ្ចេញបញ្ជីឈ្មោះអ្នកមិនទាន់បានបង់ថ្លៃសេវាប្រមូលសំរាម និងសំណល់រឹង ជាសាធារណៈតាមបណ្តាញសង្គម ឬប្រព័ន្ធផ្សព្វផ្សាយដកស្រង់ពី(Fresh News) 29,05.2020



រដ្ឋបាលសាលារាជធានីភ្នំពេញ បានអំពាវនាវឲ្យប្រជាពលរដ្ឋដែលមិនទាន់បានបង់ថ្លៃសេវាប្រមូលសំរាម និងសំណល់រឹង សូមអញ្ជើញរួសរាន់ឡើងដើម្បីទៅបង់ ដែលជាការកាតព្វកិច្ចជៀសវាងការពិន័យផ្សេងៗ។(អានបន្ត)

## ១៦.ពលរដ្ឋមួយចំនួនកាប់ដុតព្រៃឈើនៅជួរភ្នំក្រវាញ ខេត្តពោធិ៍សាត់ តែពេលសមត្ថកិច្ចចុះហាមឃាត់ បែរជាលើកគ្នាតវ៉ាដោយកាន់ដំបងកាំបិតដកស្រង់ពី(Fresh News) 29,05.2020



ប្រជាពលរដ្ឋមួយចំនួន បានចូលកាប់ដុតព្រៃឈើនៅក្នុងតំបន់អភិរក្សធនធានធម្មជាតិជួរភ្នំក្រវាញកណ្តាល ខេត្តពោធិ៍សាត់ ក្រោមហេតុផលដើម្បីយកដីធ្វើចម្ការ ប៉ុន្តែនៅពេលកម្លាំងសមត្ថកិច្ច និងមន្ត្រីអង្គការសម្ព័ន្ធមិត្តសត្វព្រៃ (Wildlife Alliance) ចុះទៅហាមឃាត់ទង្វើខុសច្បាប់នេះ បែរជាពួកគេលើកគ្នាមកតវ៉ាបែកផ្សេង ដៃប្រដាប់ដោយដំបង កាំបិត ជាមួយនឹងពាក្យសម្តីប្រមាថទៅលើកម្លាំងដែលចុះហាមឃាត់នោះ។(អានបន្ត)

## ១៧.សម្តេចក្រឡាហោម ស ខេង៖ ការបំផុសឱ្យប្រជាពលរដ្ឋឈប់សងបំណុល គឺជារឿងមិនអាចទៅរួចទេ

ដកស្រង់ពី(Fresh News) 29,05.2020



សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងថា ការបំផុសឱ្យប្រជាពលរដ្ឋកុំសងបំណុលគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ នឹងមិនអាចទៅរួចឡើយ ទោះជានៅកន្លែងណាក៏ដោយ។(អានបន្ត)

## ១៨.កុំប្រើទូរស័ព្ទពេលកំពុងបើកបរ ! ស្លាប់៣នាក់ និងរបួស២៩នាក់ ក្នុងគ្រោះថ្នាក់ចរាចរណ៍ទូទាំងប្រទេស ថ្ងៃទី២៨ ខែឧសភាម្សិលមិញ

ដកស្រង់ពី(Fresh News) 29,05.2020



យោងតាមរបាយការណ៍ របស់អគ្គស្នងការដ្ឋាននគរបាលជាតិបានឱ្យដឹងថា នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ មានករណីគ្រោះថ្នាក់ចរាចរណ៍ នៅទូទាំងប្រទេសកើតឡើងចំនួន៨លើក បណ្តាលឲ្យមនុស្សស្លាប់៣នាក់, របួសស្រាល១៣នាក់ និងរបួសធ្ងន់១៦នាក់។ (អានបន្ត)

## ព័ត៌មាន- អន្តរជាតិ

### ១. ចំនួនអ្នកឆ្លង COVID-19 លើលោកកើនដល់ជិត ៦លាននាក់ ស្លាប់ជាង ៣៦ម៉ឺននាក់ និងជាសះស្បើយជិត ២.៦លាននាក់ដកស្រង់ពី(Fresh News)29.05.2020



គិតត្រឹមម៉ោង ៧ព្រឹកថ្ងៃសុក្រ ទី២៩ ខែឧសភា ឆ្នាំ២០២០នេះ ចំនួនអ្នកឆ្លងជំងឺ COVID-19 នៅទូទាំងពិភពលោក បានកើនឡើងដល់ ៥,៩០០,៥២៧នាក់ហើយ ក្នុងនោះអ្នកស្លាប់មានចំនួន ៣៦១,៧៦៤ នាក់ និងជាសះស្បើយឡើងវិញ ២,៥៧៧,១៨១នាក់។(អានបន្ត)

### លោក ត្រាំ ចុះហត្ថលេខាលើបទបញ្ជាប្រតិបត្តិ ដើម្បីដាក់បន្ទុកលើបណ្ដាញសង្គមនៅអាមេរិក

ដកស្រង់ពី(Fresh News)29.05.2020



នៅទីបំផុតបទបញ្ជាប្រតិបត្តិមួយ ត្រូវបានចុះហត្ថលេខាហើយ ដោយប្រធានាធិបតីអាមេរិកលោក ដូណាល់ ត្រាំ ដែលមានគោលដៅដកការអនុគ្រោះផ្នែកច្បាប់មួយចំនួន ចេញពីវេទិកាបណ្ដាញសង្គមនានានៅអាមេរិក។ (អានបន្ត)

### ៣. កូរ៉េខាងត្បូងរកឃើញអ្នកឆ្លង COVID-19 ៥៨នាក់ទៀតហើយ ដែលពាក់ព័ន្ធការផ្ទុះករណីឆ្លងជាចង្កោម នៅជាយទីក្រុងសេអ៊ូលដកស្រង់ពី(Fresh News)29.05.2020



កូរ៉េខាងត្បូងហាក់កំពុងជួបប្រទះភាពភ័យខ្លាចជាថ្មី ក្រោយការផ្ទុះករណីឆ្លង COVID-19 ជាចង្កោម នៅក្នុងឃ្លាំងស្តុកទំនិញមួយ ស្ថិតនៅតំបន់ ប៊ូឈន់ (Bucheon) ជាយរដ្ឋធានីសេអ៊ូល ខណៈការរកឃើញអ្នកឆ្លងថ្មីៗចេះតែកើនឡើងវិញជាលំដាប់(អានបន្ត)

### ៤.ទីបំផុតអង់គ្លេស ត្រៀមបើកសាលារៀន និងអាជីវកម្មខ្លះឡើងវិញ ទោះបីស្ថានការណ៍ COVID-19 ស្ថិតក្នុងភាពមិនច្បាស់លាស់ដកស្រង់ពី(Fresh News)29.05.2020




នាយករដ្ឋមន្ត្រីអង់គ្លេសលោក បូរីស ចនសុន (Boris Johnson) នៅថ្ងៃព្រហស្បតិ៍សប្តាហ៍នេះ បានបង្ហាញពីគម្រោងបន្ធូរបន្ថយបន្តិចមកវិញ និងប្រកបដោយការប្រុងប្រយ័ត្ន ចំពោះវិធានការទប់ស្កាត់ការឆ្លងរីករាលដាល នៃជំងឺ COVID-19។ (អានបន្ត)

## ៥.លោក ត្រាំ ត្រៀមធ្វើសន្និសីទព័ត៌មាន «ស្តីអំពីចិន» នៅក្នុងពេលឆាប់ៗ ដោយលោកបង្ហាញការមិនពេញចិត្ត ជាខ្លាំងចំពោះចិនដកស្រង់ពី(Fresh News)29.05.2020



ប្រធានាធិបតីអាមេរិកលោក ដូណាល់ ត្រាំ បានគូសបញ្ជាក់ថា នៅថ្ងៃសុក្រសប្តាហ៍នេះ (ម៉ោងនៅវ៉ាស៊ីនតោន) លោកនឹងធ្វើសន្និសីទកាសែតមួយ ស្តីពីប្រទេសចិន ខណៈទំនាក់ទំនងរវាងប្រទេសមហាអំណាចទាំងពីរ កំពុងតែវិវឌ្ឍទៅរកភាពតានតឹងកាន់តែខ្លាំងឡើង នៅចំពោះមុខបញ្ហាហុងកុង និងផលវិបាកនៃវិបត្តិ COVID-19 ព្រមទាំងសង្គ្រាមពាណិជ្ជកម្ម។(អានបន្ត)

## ៦. ហុងកុងព្រមានទៅអាមេរិក៖ «ការដកឋានៈពិសេសរបស់ហុងកុង នឹងក្លាយជាអាវុធមុខពីរ ដែលអាចបំផ្លាញប្រយោជន៍អាមេរិកដូចគ្នា»ដកស្រង់ពី(Fresh News)29.05.2020



រដ្ឋបាលទីក្រុងហុងកុងបានព្រមាន ទៅកាន់សហរដ្ឋអាមេរិកវិញថា ការដកឋានៈពិសេសជាមជ្ឈមណ្ឌលហិរញ្ញវត្ថុសកល (global financial hub) ចេញពីទីក្រុងសេដ្ឋកិច្ចលំដាប់កំពូល ប្រចាំទ្វីបអាស៊ីមួយនេះ ប្រាកដណាស់ថានឹងក្លាយជា «អាវុធមុខពីរ» ហេតុដូច្នេះហុងកុងអំពាវនាវឲ្យ សហរដ្ឋអាមេរិក បញ្ឈប់ការលូកលាន់ចូលកិច្ចការផ្ទៃក្នុងរបស់ខ្លួន។(អានបន្ត)

## ៧.ចិនរកមិនឃើញមានករណីឆ្លង COVID-19 ថ្មីនោះទេ ក្នុងរបាយការណ៍ថ្ងៃសុក្រនេះ

ដកស្រង់ពី(Fresh News)29.05.2020



អាជ្ញាធរសុខាភិបាលចិនបានគូសបញ្ជាក់នៅថ្ងៃសុក្រ ទី២៩ ខែឧសភានេះថា ក្នុងរយៈពេលពេញមួយថ្ងៃព្រហស្បតិ៍ម្សិលមិញនេះ ប្រទេសចិនពុំមានករណីឆ្លងថ្មី នៃជំងឺ COVID-19 ឡើយ គឺមិនថាករណីឆ្លង ក្នុងស្រុកផ្ទាល់ ឬក៏ករណីនាំចូល ខណៈអ្នកទើបជាសះស្បើយវិញមានចំនួន ០៣នាក់។ (អានបន្ត)

## ៨. ស្ត្រីជាជនភៀសខ្លួនរ៉ូហ៊ីងយ៉ា រៀបរាប់ពីជីវិតតែលតោលលើផ្ទៃសមុទ្រពីរខែ ដោយមិននឹកស្មានថាអាចមកដល់បង់ក្លាដែសវិញឡើយដកស្រង់ពី(Fresh News)29.05.2020



ស្ត្រីជនជាតិម៉ូស្លីមរ៉ូហ៊ីងយ៉ាម្នាក់ បានរៀបរាប់រឿងរ៉ាវដ៏គួរឲ្យខ្លោចផ្សាបំផុតមួយ ស្តីពីការប៉ុនប៉ងលួចឆ្លងដែនចូលទៅកាន់ម៉ាឡេស៊ី ប៉ុន្តែទីបំផុតបានត្រឡប់មកជំរំភៀសខ្លួននៅបង់ក្លាដែសវិញ បន្ទាប់ពីនៅតែលតោលលើទូកកណ្តាលផ្ទៃសមុទ្រ អស់រយៈពេលប្រមាណជាពីរខែជាមួយជនភៀសខ្លួនរ៉ូហ៊ីងយ៉ាងរាប់រយនាក់ផ្សេងទៀត។(អានបន្ត)

## ៩.មិនធម្មតា! ប្រេស៊ីលបំបែកកំណត់ត្រាថ្មីដោយមានអ្នកឆ្លង COVID-19 រហូតដល់ «២៦,៤១៧នាក់ក្នុង១ថ្ងៃ»ដកស្រង់ពី(Fresh News)29.05.2020



វាជារឿងមិនធម្មតាឡើយសម្រាប់ប្រេស៊ីល ដែលកំពុងឈរនៅលំដាប់លេខ ២ ជាប្រទេសមានអ្នកឆ្លង COVID-19 ច្រើនជាងគេលើពិភពលោក បន្ទាប់ពីសហរដ្ឋអាមេរិកស្រាប់ទៅហើយនោះ ទើបតែបានបំបែកកំណត់ត្រាដ៏អាក្រក់ថ្មីមួយទៀត នោះគឺការរកឃើញអ្នកឆ្លង COVID-19 រហូតដល់ទៅ ២៦,៤១៧នាក់ ក្នុងពេលតែមួយថ្ងៃប៉ុណ្ណោះ ដែលនាំឲ្យចំនួនករណីឆ្លងសរុបកើនដល់ ៤៣៨,២៣៨ករណី។(អានបន្ត)

## ១០.ឥណ្ឌាទើបបំបែកកំណត់ត្រាថ្មីទៀតដោយមានអ្នកឆ្លង COVID-19 «៧,៤៦៦នាក់ក្នុងមួយថ្ងៃ» និងមនុស្ស១៧៥នាក់ទៀតស្លាប់!ដកស្រង់ពី(Fresh News)29.05.2020



តួលេខករណីឆ្លងប្រចាំថ្ងៃនៃជំងឺ COVID-19 នៅក្នុងប្រទេសឥណ្ឌា សម្រាប់រយៈពេល ២៤ម៉ោងកន្លងទៅនេះបានហក់ឡើងខ្ពស់បំផុតពុំធ្លាប់មាន ដោយនៅថ្ងៃសុក្រ ទី២៩ ខែឧសភា ឆ្នាំ២០២០ នេះតែម្តង អាជ្ញាធរសុខាភិបាលនៃប្រទេសអាស៊ីខាងត្បូងមួយនេះបានអះអាងថា មានរហូតដល់ ៧,៤៦៦ករណីឆ្លងថ្មី និងស្លាប់ ១៧៥នាក់តែក្នុងរយៈពេល ០១ថ្ងៃប៉ុណ្ណោះ។ (អានបន្ត)

## ១០. ផ្សារអណ្តែតទឹកដ៏ល្បីនៅថៃ ចាប់ផ្តើមបើកឡើងវិញ ដោយជិះទូកដោយឥតគិតថ្លៃដកស្រង់ពី(រស្មីកម្ពុជា)29.05.2020



អភិបាលស្រុកនៃតំបន់នេះបាននិយាយកាលពីថ្ងៃ២៧ឧសភាថា អាជីវកម្មនៅក្នុងតំបន់រួមទាំងផ្សារអណ្តែតទឹកបានកំពុងរងប៉ះពាល់ខ្លាំងបន្ទាប់ពីត្រូវបានបង្ខំឱ្យបិទជាបណ្តោះអាសន្ន ក្រោមវិធានការបិទប្រទេសរបស់រដ្ឋាភិបាល។ ជាលទ្ធផលនោះ ចំណូលពីវិស័យទេសចរណ៍បានធ្លាក់ចុះនៅក្នុងខេត្តនេះ។(អានបន្ត)

## ១១. ឪពុកសម្លាប់កាត់ក្បាលកូនស្រីអាយុ១៣ឆ្នាំបន្ទាប់ពីដឹងថានាងលង់ខ្លួនស្រឡាញ់បុរសចាស់ម្នាក់ ដកស្រង់ពី(រស្មីកម្ពុជា)29.05.2020



ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកបាននិយាយថាក្មេងស្រីជនជាតិអ៊ីរ៉ង់អាយុ ១៣ ឆ្នាំម្នាក់ ត្រូវបានកាត់ក្បាលសម្លាប់ដោយឪពុករបស់នាងដើម្បី” ការពារកិត្តិយសគ្រួសារ” ខណៈដែលនាងបានកំពុងដេក។តាមសេចក្តីរាយការណ៍បាននិយាយថា នាងរ៉ូមីណា អាសរ៉ាហ្វី ត្រូវបានសម្លាប់ដោយប្រើកណ្តៀវនៅផ្ទះរបស់នាងនៅទីក្រុងតាឡេស។(អានបន្ត)

## ១២.អតីតនាយករដ្ឋមន្ត្រីម៉ាឡេស៊ី ត្រូវបណ្តេញចេញពីបក្សចំពេលមានការតស៊ូអំណាចដកស្រង់ពី(រស្មីកម្ពុជា)

28.05.2020



អតីតនាយករដ្ឋមន្ត្រីម៉ាឡេស៊ី លោកមហាធៀ ម៉ូហាម៉ាត ត្រូវបានបណ្តេញចេញពីគណបក្សនយោបាយរបស់លោក នៅក្នុងការតស៊ូអំណាចចុងក្រោយមួយជាមួយនឹងអ្នកស្នងតំណែងពីលោក តែលោកប្តេជ្ញាប្រឆាំងនឹងចំណាត់ការនេះ។(អានបន្ត)

## ១៣.នាយករដ្ឋមន្ត្រីចិនថា ច្បាប់សន្តិសុខហុងកុងគឺដើម្បីស្ថិរភាពនិងវិបុលភាពរបស់ទីក្រុងនេះ

ដកស្រង់ពី(រស្មីកម្ពុជា)29.05.2020




នៅប៉ុន្មានម៉ោងក្រោយសភាប្រជាជនចិនអនុម័តច្បាប់សន្តិសុខសំរាប់ហុងកុង នាយករដ្ឋមន្ត្រីចិនលោក លី ឃើឈាំង បាននិយាយកាលពីថ្ងៃព្រហស្បតិ៍ទី២៨ឧសភាថា ការអនុម័តច្បាប់សន្តិសុខជាតិហុងកុងគឺដើម្បី«ស្ថិរភាពនិងវិបុលភាព»រយៈពេលវែងរបស់ទីក្រុងនេះប៉ុណ្ណោះ។(អានបន្ត)

## ១៤. រដ្ឋាភិបាលហុងកុងព្រមានថាការដកចេញនូវឋានៈពិសេសរបស់ហុងកុងពីសំណាក់អាមេរិក ជា “កាំបិតមុខពីរ”ដកស្រង់ពី(រស្មីកម្ពុជា)29.05.2020



រដ្ឋាភិបាលហុងកុងបានព្រមានរបបក្រុងវ៉ាស៊ីនតោនថាការដកឋានៈពិសេសពីសំណាក់សហរដ្ឋអាមេរិក ដែលធ្លាប់បានគាំទ្រទីក្រុងនេះជាមជ្ឈមណ្ឌលហិរញ្ញវត្ថុពិភពលោក អាចជា “កាំបិតមុខពីរ” និងជំរុញឱ្យសហរដ្ឋអាមេរិកបញ្ឈប់ការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង។(អានបន្ត)

## ១៥.ប្រេស៊ីលមានអ្នកស្លាប់ដល់ខ្ទង់២៥.០០០នាក់ ខណៈប្រទេសនេះក្លាយជាចំណុចផ្ទុះធំមួយទៀតនៃកូវីដ១៩

ដកស្រង់ពី(រស្មីកម្ពុជា)29.05.2020



ចំនួនអ្នកស្លាប់សរុបដោយកូវីដ១៩ នៅប្រេស៊ីលបានកើនដល់ខ្ទង់ ២៥.០០០ នាក់កាលពីថ្ងៃពុធទី២៧ឧសភា ខណៈប្រទេសនេះបានក្លាយជាចំណុចផ្ទុះធំមួយ ទៀតនៃកូវីដ១៩ នៅលើពិភពលោកក្រសួងសុខាភិបាលនិយាយថា ខ្លួនបានបញ្ជាក់ករណីស្លាប់ថ្មីចំនួន ១.០៨៦ ក្នុងពេល ២៤ម៉ោងចុងក្រោយវាជាលើកទី៥ហើយដែលចំនួនអ្នកស្លាប់កើនលើស ១.០០០នាក់ក្នុងមួយថ្ងៃ ចាប់តាំងពីវិបត្តិមេរោគនេះបានស្ទុះឡើងខ្លាំងកាលពីមួយសប្តាហ៍មុន។(អានបន្ត)

## ១៦.អាម៉េរិកប្រឈមការតវ៉ាប្រឆាំងបន្ថែមទៀតដោយសារតែប៉ូលិសសម្លាប់បុរសស្បែកខ្មៅ

**ដកស្រង់ពី(រស្មីកម្ពុជា)29.05.2020**



អាជ្ញាធរនៅក្រុងមីនីប៉ូលិស និងក្រុង សេន ផល បានទទួលកម្លាំងជំនួយមកពីកងឆ្មាំជាតិកាលពីថ្ងៃព្រហស្បតិ៍ទី២៨ឧសភា នៅពេលទីក្រុងទាំង២នេះប្រឈមការតវ៉ាប្រឆាំងថ្មីនិងអំពើហិង្សាដែលបង្កឡើងពីការដែលប៉ូលិសស្បែកសម្នាក់ដាក់ខ្នោះជាន់កបុរសស្បែកខ្មៅម្នាក់រហូតដល់ថប់ដង្ហើមស្លាប់។(អានបន្ត)

## ១៧.តុលាការ ICC អនុញ្ញាតឱ្យអតីតប្រធានាធិបតីកូតឌីវ័រចាកចេញពីបែលហ្ស៊ិក **ដកស្រង់ពី(រស្មីកម្ពុជា) 29.05.2020**



តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) កាលពីថ្ងៃព្រហស្បតិ៍ទី២៨ឧសភាបាននិយាយថា អតីតប្រធានាធិបតីកូតឌីវ័រលោក ឡូរ៉ង់ ក្បាកបូ (Laurent Gbagbo) អាចចាកចេញពីបែលហ្ស៊ិកក្រោមលក្ខខណ្ឌមួយចំនួនបន្ទាប់ពីការដោះលែងរូបលោកកាលពីឆ្នាំមុនជុំវិញអំពើហិង្សាក្រោយការបោះឆ្នោតដែលបានសម្លាប់មនុស្ស ៣០០០ នាក់។(អានបន្ត)

## ១៨. សហរដ្ឋអាម៉េរិកប្រកាសផ្តល់រង្វាន់ដល់៣លានដុល្លារសម្រាប់ការចាប់ខ្លួនមេដឹកនាំម្នាក់នៃក្រុមISIS

**ដកស្រង់ពី(រស្មីកម្ពុជា)29.05.2020**



សហរដ្ឋអាម៉េរិកបាននិយាយកាលពីថ្ងៃព្រហស្បតិ៍ទី២៨ឧសភាថា ខ្លួននឹងផ្តល់ប្រាក់រហូតដល់ទៅ៣ លានដុល្លារសម្រាប់ការចាប់ខ្លួនមេដឹកនាំជាន់ខ្ពស់ម្នាក់នៃចលនារដ្ឋអ៊ីស្លាម(ក្រុមISIS)ដែលបានគ្រប់គ្រប់លើវីដេអូប្រហារជីវិតដ៏ឃោរឃៅរបស់ក្រុមជ្រុលនិយមនេះ។(អានបន្ត)

## ១៩.នាយករដ្ឋមន្ត្រីអង់គ្លេស ប្រកាសឲ្យបង្កើន ការប្រុងយ័ត្នគ្រាបន្ធូរបន្ថយ ការបិទប្រទេស ខណៈអ្នកស្លាប់ដោយជំងឺកូវីដ១៩ មានរហូតដល់ជាង ៣៧.០០០នាក់ **ដកស្រង់ពី(DAP)29.05.2020**



នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ថា កាលពីថ្ងៃព្រហស្បតិ៍ លោក Boris Johnson នាយករដ្ឋមន្ត្រីអង់គ្លេស បានប្រកាសឲ្យមានការ "កំណត់" និង"ប្រុងប្រយ័ត្នខ្ពស់" នៅគ្រាដែលមានការបន្ធូរបន្ថយ នូវវិធានការបិទប្រទេស ដោយសារវីរុសកូរ៉ូណា នៅក្នុងប្រទេស ។(អានបន្ត)

## ២០.វៀតណាម ត្រូវបានគេរាយការណ៍ថា មិនមានអ្នកឆ្លងជំងឺកូវី១៩ ថ្មីនោះទេ ដកស្រង់ពី(DAP)29.05.2020




នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ថា ក្រសួងសុខាភិបាល បានឲ្យដឹងថា វៀតណាម ត្រូវបានគេរាយការណ៍ថា មិនមានករណីថ្មីនៃអ្នកឆ្លង ជំងឺកូវីដ ១៩នោះទេ គិតត្រឹមថ្ងៃព្រហស្បតិ៍នេះ ជាមួយគ្នានេះដែរ ត្រូវបានគេ បញ្ជាក់ថា មានករណីដដែលចំនួន ៣២៧នាក់ ហើយមិនមានអ្នកស្លាប់ ឡើយ ។(អានបន្ត)

## ២១.សហភាព អារ៉ាប់រួម មានអ្នកឆ្លងជំងឺកូវីដ១៩ កើនដល់ជាង ៣ម៉ឺននាក់ដកស្រង់ពី(DAP)29.05.2020



នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ថា សហភាពអារ៉ាប់រួម (UAE)នៅថ្ងៃ ព្រហស្បតិ៍នេះ បានប្រកាសថា មានករណីថ្មីជំងឺកូវីដ១៩ចំនួន៥៦៣ នាក់ ដែលនាំឲ្យអ្នកឆ្លងជំងឺ នៅក្នុងប្រទេសបានកើនឡើងដល់ ៣២.៥៣២នាក់ ។ (អានបន្ត)

## ២២.អ៊ីរ៉ង់ មានអ្នកឆ្លងជំងឺកូវីដ១៩ សរុបកើន ដល់ជាង ១៤ម៉ឺននាក់ដកស្រង់ពី(DAP)29.05.2020



នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ថា ក្រសួងសុខាភិបាល បាន បង្ហាញនូវព័ត៌មានថ្មីៗថា គិតត្រឹមថ្ងៃព្រហស្បតិ៍នេះ អ៊ីរ៉ង់ ត្រូវបានចុះ បញ្ជី ដែលមានអ្នកឆ្លងជំងឺកូវីដ១៩ថ្មី ចំនួន២.២៥៨នាក់ ដែលនាំឲ្យ តួលេខអ្នកឆ្លងជំងឺសរុប នៅក្នុងប្រទេស បានកើនឡើងដល់ ១៤៣.៨៤៩នាក់ គិតចាប់តាំងពីមានការផ្ទុះជំងឺ កាលពីចុងខែកុម្ភៈ ។ (អានបន្ត)

## ២៣. ម៉ាឡេស៊ី ត្រូវបានគេរាយការណ៍ថា មានអ្នកឆ្លងជំងឺកូវីដ១៩ កើនឡើងដល់ជាង ៧ពាន់នាក់ ដកស្រង់ពី(DAP)29.05.2020



នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ថា ក្រសួងសុខាភិបាល បានឲ្យដឹង ថា ម៉ាឡេស៊ី ត្រូវបានគេរាយការណ៍ថា មានអ្នកឆ្លងជំងឺកូវីដ១៩ថ្មីចំនួន ១០នាក់ គិតត្រឹមថ្ងៃព្រហស្បតិ៍នេះ អ្នកកើនឡើងថ្មី ទាបគិតចាប់ពីពាក់ក ណ្តាលខែមីនា ដែលនាំឲ្យតួលេខសរុប បានកើនឡើងដល់៧.៦២៩នាក់ ។(អានបន្ត)

## ២៤.អាល្លឺម៉ង់ មានអ្នកឆ្លងជំងឺកូវីដ១៩ កើនឡើង ដល់ជិត ១៨ម៉ឺននាក់ដកស្រង់ពី(DAP)29.05.2020




នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ថា វិទ្យាស្ថាន Robert Koch Institute (RKI) បានប្រកាសឲ្យដឹងនៅថ្ងៃព្រហស្បតិ៍ថា អ្នកឆ្លងជំងឺកូវីដ១៩ថ្មី នៅក្នុងប្រទេសអាល្លឺម៉ង់ គិតជាមធ្យមមាន ចំនួន៣៥៣នាក់ ក្នុង១ថ្ងៃ នាំឲ្យចំនួនអ្នកឆ្លងជំងឺ កើនឡើងដល់១៧៩.៧១៧នាក់ ។ (អានបន្ត)

## ២៥.សមាជិកសភារុស្ស៊ី ៖ មូស្គូមិនបានបញ្ជូន បុគ្គលិកយោធា ទៅលីប៊ីទេដកស្រង់ពី(DAP)29.05.2020



ដោយលើកយក សម្តីរបស់លោក Vladimir Dzhabarov អនុប្រធានទីមួយ នៃគណៈកម្មាធិការកិច្ចការអន្តរជាតិ របស់រដ្ឋសភា កាសែតរុស្ស៊ី Interfax បានរាយការណ៍នៅថ្ងៃពុធនេះថា ប្រទេសរុស្ស៊ី មិនបានបញ្ជូន បុគ្គលិកយោធា ទៅប្រទេសលីប៊ីនោះទេ ហើយរដ្ឋសភា របស់រុស្ស៊ី មិនបានទទួលសំណើឲ្យអនុម័ត ការបញ្ជូនបែបនេះ នោះឡើយ ។(អានបន្ត)

## ២៦.សមាជិកព្រឹទ្ធសភារុស្ស៊ី រិះគន់អាមេរិក សម្រាប់ការបញ្ចប់ការលើកលែង ទណ្ឌកម្ម លើទីតាំង នុយក្លេអ៊ែរអ៊ីរ៉ង់

ដកស្រង់ពី(DAP)29.05.2020



សមាជិកព្រឹទ្ធសភា អាមេរិក លោក Vladimir Dzhabarov បាននិយាយនៅថ្ងៃព្រហស្បតិ៍នេះថា ការសម្រេចចិត្ត របស់អាមេរិកបញ្ចប់ ការលើកលែងទណ្ឌកម្ម ដែលអនុញ្ញាតឲ្យមានការងារ ខ្លះដំណើការ នៅទីតាំងនុយក្លេអ៊ែរអ៊ីរ៉ង់នោះ នឹងត្រឹមតែរុញច្រាន ទីក្រុងតេអេរ៉ង់ឲ្យអភិវឌ្ឍ ផលិតអាវុធនុយក្លេអ៊ែ ។(អានបន្ត)

## ២៧.ក្រុមជំនួញ អាមេរិកនិងអឺរ៉ុប ជំរុញចិនឲ្យអនុញ្ញាត បុគ្គលិកបរទេសវិល ត្រឡប់ទៅវិញដកស្រង់ពី(DAP)29.05.2020



ក្រុមជំនួញអាមេរិកនិងអឺរ៉ុប កំពុងតែចរចាជំរុញប្រទេសចិន ឲ្យអនុញ្ញាតឲ្យបុគ្គលិកបរទេស វិលត្រឡប់ចូលទៅចិនវិញ ក្រោយទីក្រុងប៉េកាំង បិទព្រំដែនរបស់ខ្លួន ចាប់តាំងពីចុងខែមីនា ចំពោះអ្នកមិនមែនជាជនជាតិចិន ដើម្បីទប់ស្កាត់ការរាតត្បាត នៃវីរុសកូរ៉ូណា ។(អានបន្ត)

## ២៨.នាយករដ្ឋមន្ត្រីចិន ៖ អាមេរិកនិងចិន គួរតែគោរពផល ប្រយោជន៍គ្នា ទៅវិញទៅមកដកស្រង់ពី (DAP)29.05.2020



នាយករដ្ឋមន្ត្រីចិន លោក Li Keqiang នៅថ្ងៃព្រហស្បតិ៍នេះ បានមានប្រសាសន៍ថា ប្រទេសចិននិងសហរដ្ឋអាមេរិក គួរតែគោរពផលប្រយោជន៍ស្នូលរបស់គ្នាទៅវិញទៅមក និងគ្រប់គ្រងភាពខ្វែងគំនិតគ្នា ហើយការបំបែកសេដ្ឋកិច្ច គឺមិនល្អសម្រាប់ ពិភពលោកនោះទេ។អានបន្ត)

## ២៩.អាមេរិក បញ្ចប់ការលើកលែង ពាក់ព័ន្ធកិច្ចព្រមព្រៀង នុយក្លេអ៊ែរអ៊ីរ៉ង់ដកស្រង់ពី(DAP)29.05.2020



រដ្ឋបាលសហរដ្ឋអាមេរិក តាមសេចក្តីរាយការណ៍ បានប្រកាសនៅថ្ងៃពុធសប្តាហ៍នេះថា ខ្លួននឹងបញ្ចប់ការលើកលែង ទណ្ឌកម្មទាំងអស់ ដែលអនុញ្ញាតឲ្យក្រុមហ៊ុនបរទេស ធ្វើការងារនៅបរិវេណនុយក្លេអ៊ែ របស់ប្រទេសអ៊ីរ៉ង់ ហើយនេះគឺជា ការធ្វើឲ្យកាន់តែធ្ងន់ធ្ងរឡើង របស់ទីក្រុងវ៉ាស៊ីនតោន ពីកិច្ចព្រមព្រៀងឆ្នាំ២០១៥ ដែលមានគោលបំណង ទប់ស្កាត់មិនឲ្យទីក្រុងតេអេរ៉ង់ កសាងអាវុធនុយក្លេអ៊ែ ។(អានបន្ត)

## ៣០.ព័ត៌មានអន្តរជាតិឥណ្ឌានឹង សាកល្បងផលិតថ្នាំ ដែលផ្សំចេញពីលាមកគោ និងទឹកនោមគោ ដើម្បីព្យាបាលមេរោគកូវីដ១៩ដកស្រង់ពី(DAP)29.05.2020




ដំណាក់កាលនេះ ត្រូវបានកំណត់ នៅក្នុងរដ្ឋកំណើត របស់នាយករដ្ឋមន្ត្រីឥណ្ឌា លោកណារិនដ្រា ម៉ូឌី ដើម្បីសាកល្បងប្រសិទ្ធភាពនៃថ្នាំដែលបានមកពីផលិតផល សំខាន់ៗចំនួន ៥ ដែលបានដកស្រង់ពីគោក្របី ក្នុងនោះរួមមាន ទឹកដោះគោ ខ្លាញ់ចម្រាញ់ចេញពីទឹកដោះគោ ប៉័រចម្រាញ់ពីទឹកដោះគោ អាចម៍គោ និងទឹកនោមគោ ដើម្បីយកមកព្យាបាលជំងឺកូវីដ – ១៩ ។(អានបន្ត)

## ៣១.វៀតណាម ត្រូវបានអញ្ជើញ ឱ្យចូលរួមសមយុទ្ធ ជើងទឹកធំបំផុត នៅលើពិភពលោកលើកទី២ នៅអាមេរិក ខណៈចិន គ្មានក្នុងបញ្ជីដកស្រង់ពី(DAP29.05.2020



ប្រទេសវៀតណាម នឹងក្លាយជាភ្ញៀវ នៅក្នុងសមយុទ្ធ RIMPAC ឆ្នាំ ២០២០ ដោយចូលរួមជា មួយប្រទេសជាង ២០ ផ្សេងទៀត នៅក្នុងព្រឹត្តិការណ៍ ដែនសមុទ្រអន្តរជាតិ ចំណែកប្រទេសចិន មិនត្រូវបានគេអញ្ជើញ ឱ្យចូលរួមក្នុងសមយុទ្ធនេះទេ ។ (អានបន្ត)

## ៣២.ទូតអាមេរិក ប្រចាំកម្ពុជា៖ ការផ្តល់ឈាមមានន័យថា ផ្តល់ដល់អ្នកដទៃ នូវឱកាសមួយទៀត ក្នុងការបន្តជីវិត

**ដកស្រង់ពី(DAP29.05.2020**



ស្របពេលដែលប្រទេសកម្ពុជា កំពុងខ្វះខាតឈាម នៅក្នុងស្តុកនោះ លោកW. Patrick Murphy ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា បានដឹកនាំមន្ត្រីទៅផ្តល់ឈាម ដើម្បីទុកសង្គ្រោះជីវិត អ្នកកំពុងត្រូវការឈាមយោងតាមគេហទំព័រហ្វេសប៊ុក របស់ស្ថានទូតអាមេរិកប្រចាំកម្ពុជា បានឲ្យដឹងថា "ប្រទេសកម្ពុជាកំពុងតែខ្វះខាតខ្លាំង នូវឈាមនៅក្នុងស្តុក នៅក្នុងអំឡុងពេល នៃរោគរាតត្បាត នេះ។ (អានបន្ត)

## ៣៣.ស្ថានទូតអង់គ្លេស នៅកូរ៉េខាងជើង ត្រូវបិទបណ្តោះអាសន្ន ខណៈបុគ្គលិកទូតទាំងអស់ ត្រូវចាកចេញពីប្រទេសនេះ

**ដកស្រង់ពី(DAP29.05.2020**



ឯកអគ្គរដ្ឋទូតចក្រភពអង់គ្លេស ប្រចាំនៅកូរ៉េខាងជើងលោក Colin Crooks បាននិយាយ នៅថ្ងៃព្រហស្បតិ៍ថា ស្ថានទូតអង់គ្លេស ប្រចាំនៅកូរ៉េខាងជើង ត្រូវបានបិទជាបណ្តោះអាសន្ន ហើយបុគ្គលិកទាំងអស់ បានចាកចេញពីប្រទេសនេះ ចំពេលមានការរឹតត្បិតទាក់ទងនឹងមេរោគដែលត្រូវបានណែនាំ ដោយរដ្ឋាភិបាលទីក្រុងព្យុងយ៉ាង។(អានបន្ត)

## ៣៤.អាមេរិក លើកពេលបាញ់បង្ហោះ យានអវកាសពាណិជ្ជកម្ម ទៅថ្ងៃសៅរ៍វិញ ដោយសារអាកាសធាតុមិនល្អ

**ដកស្រង់ពី(DAP29.05.2020**



សហរដ្ឋអាមេរិកនៅថ្ងៃពុធ បានពន្យាពេល នៃការបាញ់បង្ហោះ យានអវកាសពាណិជ្ជកម្ម ដែលដឹកអ្នកអវកាសពីរនាក់ ដោយសារតែស្ថានភាព អាកាសធាតុមិនល្អ ជាមួយនឹងការប៉ុនប៉ង បន្ទាប់ពីគ្រោងនឹងធ្វើនៅរសៀលថ្ងៃសៅរ៍វិញ។
(អានបន្ត)

## ៣៥. ព័ត៌មានអន្តរជាតិUNC នៅតែមិនអាចបញ្ជាក់ថា តើកូរ៉េខាងជើង ចាប់ផ្តើមបាញ់ប្រហារនៅ DMZ មុន ឬយ៉ាងណា

**ដកស្រង់ពី(DAP)29.05.2020**



បញ្ជាការអង្គការ សហប្រជាជាតិ (UNC) បានឲ្យដឹងថា ខ្លួនមិនអាចកំណត់ ឱ្យបានច្បាស់លាស់ ថាតើកូរ៉េខាងជើង បានចាប់ផ្តើមការដោះដូរកាំភ្លើង ជាមួយកូរ៉េខាងត្បូង ដោយចេតនា ឬដោយកំហុសនោះទេ ប៉ុន្តែបានរកឃើញថា ភាគីទាំងពីរបានរំលោភ លើកិច្ចព្រមព្រៀងឈប់បាញ់។
(អានបន្ត)